ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# ស្ថានទូតកម្ពុជានៅម៉ាឡេស៊ី អន្តរាគមជួយសង្គ្រោះពលករ-ពលការិនីខ្មែរ៩នាក់

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានអន្តរាគមដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលការិនីខ្មែរចំនួន**៨នាក់** ដែលជាប់ឃុំនៅជំរុំ Bukit Jalil នៃទីក្រុងគូឡាឡាំពួរ និងពលករខ្មែរ**ម្នាក់** ដែលពុំអាចទ្រាំទ្រនឹងការងារលំបាកនៅម៉ាឡេស៊ី ដូចខាងក្រោម៖

១. ពលការិនី **ឡ.ស.ភ** អាយុ២៨ឆ្នាំ មកពីស្រុកកំពង់ស្ពឺ ខេត្តកំពង់ស្ពឺ

២. ពលការិនី **ណ.គ.ហ** អាយុ២៧ឆ្នាំ មកពីស្រុកកងមាស ខេត្តកំពង់ចាម

៣. ពលការិនី **ស.ខ** អាយុ៣៣ឆ្នាំ មកពីស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ

៤. ពលការិនី **ផ.ស.ល** អាយុ២៣ឆ្នាំ មកពីស្រុកត្រាំកក់ ខេត្តតាកែវ

៥. ពលការិនី **ប.ស.វ** អាយុ៣៣ឆ្នាំ មកពីស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង

៦. ពលការិនី **ប.ច.ល** អាយុ១៩ឆ្នាំ មកពីស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង

៧. ពលការិនី **ស.ភ** អាយុ៣៦ឆ្នាំ មកពីស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល

៨. ពលការិនី **ឆ.ស.រ** អាយុ១៧ឆ្នាំ មកពីស្រុកព្រះស្ដេច ខេត្តព្រៃវែង។

ពលការិនីទាំង**៨នាក់** ត្រូវបានមេខ្យល់បោកបញ្ឆោតនាំធ្វើដំណើរតាមរថយន្តឆ្លងកាត់ប្រទេសថៃទៅម៉ាឡេស៊ី ដើម្បីធ្វើការជាអ្នកបោសសំអាត កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦។ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៦ នគរបាលម៉ាឡេស៊ីបានចាប់ខ្លួនពលការិនីទាំង**៨នាក់** ពីបទរស់នៅនិងធ្វើការខុសច្បាប់។

បន្ទាប់ពីបានទទួលព័ត៌មានពីការដោះលែងពលការិនីទាំង៨នាក់ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ មន្ត្រីស្ថានទូតបានទៅសួរសុខទុក្ខ និងឧបត្ថម្ភសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ ព្រមទាំងសម្របសម្រួលជាមួយអាជ្ញាធរម៉ាឡេស៊ី ក្នុងការរៀបចំធ្វើមាតុភូមិនិវត្តន៍ ជូនដល់ពលការិនីផងដែរ។

ស្ថានទូតបានឧបត្ថម្ភសំបុត្រយន្តហោះជូនពលការិនីខ្មែរទាំង**៨នាក់** ហើយពួកគេនឹងធ្វើដំណើរមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅថ្ងៃទី **០៥** ខែ **មេសា** ឆ្នាំ **២០១៧** វេលាម៉ោង**១៥:៥៥** នាទីរសៀល តាមជើងយន្តហោះ Ak534 ។

៩. ពលករឈ្មោះ **វ.អ.ហ** អាយុ២៦ឆ្នាំ មកពីស្រុកជីក្រែង ខេត្តសៀមរាប បានទៅម៉ាឡេស៊ី ធ្វើការជាអ្នកបើកបររថយន្ត កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ តាមរយៈមេខ្យល់។ ដោយធ្វើការលំបាក ពលករបានទៅស្ថានទូតនៅថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ ស្នើសុំជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

ក្រោមកិច្ចអន្តរាគមន៍របស់ស្ថានទូត នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ និយោជករបស់ពលករ បានប្រគល់លិខិតឆ្លងដែន និងសំបុត្រយន្តហោះដល់ពលករ។

ពលករ **វ.អ.ហ** បានមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅថ្ងៃទី**០១** ខែ **មេសា** ឆ្នាំ**២០១៧** វេលាម៉ោង**១៥:៥៥** នាទីរសៀល តាមជើងយន្តហោះAK534 ៕

ភ្នំពេញ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ